# ពីនេះពីនោះ

អំណាចប្រជាពលរដ្ឋជំនះភាពក្រីក្រ



លេខរៀងទី
០២ មីនា ២០១៩

OXFAM

# មាតិកា


វិចារណកថា ៤

ក្ដីស្រលាញ់ចម្រុះ ៦

រឿងរបស់យើង ១០

ទស្សនវិស័យ ១៦

ព្រឹត្តិការណ៍ខាងមុខ ២០

ព័ត៌មាន ២១

អ្នកស្ម័គ្រចិត្ត ២៣

អំពីអ្នកស្ម័គ្រ ២៤

សូមអរគុណដែលគូទាំងអស់គ្នា! ២៥

# វិចារណកថា

**មិត្តជាទីរាប់អាន**!

តាងនាមឱ្យអង្គការអុកស្វាម ខ្ញុំសូមជូនពរសម្តេច លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា និងក្រុមគ្រួសារទាំងអស់ទទួលបាននូវពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរ និងជោគជ័យ ក្នុងឆ្នាំថ្មី ឆ្នាំ២០១៩ នេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកអ្នកដែលបានអានការចេញផ្សាយជាលើកដំបូងរបស់ "ពីនេះពីនោះ" និងចំពោះការផ្តល់មកវិញនូវមតិ ដែលមានអត្ថន័យស្ថាបនា និងលើកទឹកចិត្ត!

ឆ្នាំ២០១៩ គឺជាខួបលើកទី៤០ នៃការបញ្ចប់របបខ្មែរក្រហមដែលបង្កការស្លាប់ និងការកាប់សម្លាប់រង្គាល ដោយបន្សល់ទុកស្នាមរបួសជាអចិន្ត្រៃយ៍ និងភាពតក់ស្លុតយ៉ាងជ្រាលជ្រៅ ប៉ះពាល់ដល់ស្មារតីរបស់ប្រជាជនរាប់លាននាក់នៅក្នុងប្រទេសកម្ពុជា។ ឆ្នាំនេះក៏ជាខួបទី៤០ឆ្នាំផងដែរ សម្រាប់អង្គការអុកស្វាម ចាប់តាំងពីពេលដែលអង្គការនេះចាប់ផ្តើមធ្វើអន្តរាគមន៍ផ្នែកមនុស្សធម៌ដំបូងរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា រួមគ្នាជាមួយភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិផ្សេងទៀត។

នៅឆ្នាំ១៩៧៩ អង្គការអុកស្វាមបានធ្វើការអំពាវនាវជាលើកដំបូងរកប្រាក់ជំនួយមនុស្សធម៌ចំនួន ១០ម៉ឺនផោន ហើយក្នុងរយៈពេលបីខែប៉ុណ្ណោះ ការអំពាវនាវនេះបានវាយអង្គាសរហូតដល់ទៅ ៣លានផោន សម្រាប់យកមក "ផ្គត់ផ្គង់ស្បៀងអាហារដល់កម្ពុជា"។ Blue Peter ជាកម្មវិធីទូរទស្សន៍ពេញនិយមមួយសម្រាប់កុមារនៅចក្រភពអង់គ្លេសបានធ្វើការចាក់ផ្សាយអំពីយុទ្ធនាការកៀរគរមូលនិធិនេះពីទស្សនិកជនវ័យក្មេងរាប់លាននាក់របស់ខ្លួន។ នៅពេលដែលខ្ញុំអានអត្ថបទកាសែតមួយអំពីយុទ្ធនាការនេះ រូបខ្ញុំមានក្តីរំភើបក្រៃលែងនៅពេលដែលបានដឹងតាមរយៈអត្ថបទ




RAY GREEN

The whole of Youlgreave, Derbyshire, turned out for a Cambodian charity sale yesterday

## Cash pours in for Cambodia

by JUDITH JUDD



នោះថា ក្មេងស្រីម្នាក់អាយុ៤ឆ្នាំ សុខចិត្តលក់វត្ថុលេង ដ៏ស្អាតរបស់ខ្លួន ដើម្បីយកប្រាក់មកធ្វើវិភាគទាន សម្រាប់ទិញអាហារឱ្យក្មេងៗកម្ពុជាជាច្រើននាក់ ដែលកំពុងតែរស់ក្នុងភាពស្រេកឃ្លានដូចរូបខ្ញុំដែរ។ ពេលនោះ មានមនុស្សចម្លែកវ័យក្មេងច្រើននាក់ណាស់ ដែលបានបើកបេះដូងរបស់ខ្លួន ធ្វើទានសប្បុរសដល់ពួកយើង។ រូបខ្ញុំស្ថិតនៅក្នុងចំណោមក្មេងៗកម្ពុជា ដែលកុមារីអង់គ្លេសរូបនោះមិនបានស្គាល់ទេ ប៉ុន្តែចង់ជួយ។ ម្តាយរបស់ខ្ញុំត្រូវទៅដក់ស្ទូងនៅវាលស្រែ ជីដូនរបស់ខ្ញុំ ចិញ្ចឹមខ្ញុំដោយទឹកដែលរំងាស់ពីអង្ករងជំនួសឱ្យទឹកដោះ។ នៅពេលដែលខ្ញុំចាប់ផ្តើមធ្វើការនៅអុកស្វាម ខ្ញុំបានស្រាវជ្រាវរករូបថត និងឯកសារចាស់ៗអំពីជំនាន់នោះយកមកមើល ដើម្បីស្វែងយល់ថាតើរូបខ្ញុំចេញពីប្រភពណាមក។ ខ្ញុំបានប្រទះឃើញរូបថត និងវីដេអូជាច្រើន ដែលនាំមកនូវអារម្មណ៍ច្របូកច្របល់ដល់រូបខ្ញុំក្នុងនាមជាជនកម្ពុជាមួយរូប ដែលធំដឹងក្តីនៅក្នុងជំនាន់នោះ។ កម្ពុជាបានឆ្លងកាត់រឿងរ៉ាវយ៉ាងច្រើន ប៉ុន្តែប្រទេសនេះនៅមានដំណើរដ៏វែងឆ្ងាយទៀត ដើម្បីទៅដល់គោលដៅដែលខ្លួនសក្តិសមនឹងទៅដល់។

ពេលខ្ញុំដដែកជាមួយបុគ្គលិកអុកស្វាមទាំងខ្មែរ និងបរទេសដែលគាត់ធ្វើការនៅកំឡុងឆ្នាំ ៧០ និង៨០ ខ្ញុំភ្ញាក់ផ្អើលនឹងអ្វីដែលពួកគាត់បានលើកឡើង ហើយនៅតែជាការពិតរហូតមកដល់សព្វថ្ងៃនេះ ដែលថា៖

ភាគីអភិវឌ្ឍពាក់ព័ន្ធទាំងអស់ និងរាជរដ្ឋាភិបាល ត្រូវតែខិតខំធ្វើការជាមួយគ្នា និងអត់អោនឱ្យគ្នាទៅវិញទៅមក ដើម្បីកសាងទំនុកចិត្តរវាងគ្នានិងគ្នាបន្តិចម្តងៗ។ ភាពក្រីក្រមានលក្ខណៈស្មុគស្មាញណាស់។ ភាពជាដៃគូពិតប្រាកដ និងការប្តេជ្ញាចិត្ត គឺជាភាពចាំបាច់ខ្វះមិនបាន ដើម្បីឈានទៅលុបបំបាត់ភាពក្រីក្រ។

ខ្ញុំសង្ឃឹមជឿជាក់ថា ឆ្នាំ២០១៩ នឹងជាឆ្នាំដែលនាំមកនូវការយល់គ្នាទៅវិញទៅមកកាន់តែប្រសើរ និងភាពជាដៃគូកាន់តែប្រកបដោយអត្ថន័យនៅក្នុងចំណោមតួអង្គទាំងអស់ ដើម្បីជាប្រយោជន៍ដល់មនុស្សជំនាន់ក្រោយៗទៀតរបស់កម្ពុជា។

*នៅទីបញ្ចប់ យើងខ្ញុំនៅតែចង់បានមតិពីអ្នកទាំងអស់គ្នា! ដូច្នេះ សូមផ្ញើបទអត្ថាធិប្បាយ ឬអត្ថបទបញ្ចេញយោបល់របស់អ្នកទៅកាន់អ៊ីមែល PineehPinooh.Cambodia@oxfam.org ហើយអត្ថបទណាដែលគួរឱ្យចាប់អារម្មណ៍ជាងគេនឹងត្រូវបានយកទៅចុះផ្សាយលើទំព័រ Perspectives របស់យើង!*

*ខ្ញុំសង្ឃឹមថាលោកអ្នករីករាយជាមួយ "ពីនេះពីនោះ"!*

**សូមជូនពរបវរប្រសើរ និងរីករាយឆ្នាំថ្មី!**
**សូលីន**

# ក្ដីស្រលាញ់ចម្រុះ



## យ៉ូកូ មាន និង យ៉ូកូ ហ្សាណា



ទោះ ហ្សាណា រស់នៅក្នុងប្រទេសកម្ពុជា ហើយ មាន រស់នៅសហរដ្ឋអាមេរិកក៏ដោយ ក៏គេទាំងពីរនាក់តែងតែសាសងគ្នាជាទៀងទាត់នៅលើហ្វេសប៊ុក។ ថ្ងៃមួយ មាន បានមកលេងប្រទេសកម្ពុជា ហើយបានធ្វើឱ្យ ហ្សាណា មានការភ្ញាក់ផ្អើល មិនយូរប៉ុន្មានអ្នកទាំងពីរក៏ណាត់ជួបគ្នាចេញដើរលេងកសាងទំនាក់ទំនងស្នេហា។ ម្ដាយរបស់ ហ្សាណា មិនសូវជាសប្បាយចិត្តទេជាមួយទំនាក់ទំនងរវាងអ្នកទាំងពីរនៅក្នុងរយៈពេលពីរឆ្នាំដំបូង ដូច្នេះពួកគេប្រឹងតស៊ូជម្នះខ្លាំងណាស់។ យ៉ាងណាក៏ដោយ សេចក្ដីស្នេហារបស់គេនៅរស់រានមានជីវិត ហើយពួកគេក៏នៅតែបន្តណាត់ជួបគ្នា មិនថានៅឆ្ងាយពីគ្នា និងមានឧបសគ្គរាំងរាំងឡើយ។ យ៉ូកូ មាន ធ្វើការនៅអាកាសយានដ្ឋាន ហើយ ហ្សាណា កំពុងរៀនដើម្បីរកការងារធ្វើនៅសហរដ្ឋអាមេរិក ដែលអ្នកទាំងពីរកំពុងរស់នៅជាមួយគ្នា។ ហ្សាណា មានក្ដីរំភើបក្រៃលែងដោយបានភ្ជាប់ពាក្យ ហើយរៀបការជាមួយគូសំណព្វចិត្តរបស់ខ្លួន!

## ស៊ីង សុផាណា និង ផេង សាញ



សុផាណា និង សាញ ជួបគ្នាតាមហ្វេសប៊ុក ហើយក្រោយមកកាន់តែស្គាល់គ្នាខ្លាំងឡើងតាមរយៈការឆ្លើយឆ្លងសារគ្នា។ ពីរឆ្នាំក្រោយមកទៀត ពួកគេសម្រេចចិត្តថាត្រូវជួបមុខគ្នាផ្ទាល់ ហើយតាំងពីពេលនោះមកអ្វីៗទៀតគ្រាន់តែជារឿងអតីតកាលប៉ុណ្ណោះ។ បច្ចុប្បន្ន សុផាណា ជាអ្នកកែច្នៃម៉ូត រីឯ សាញ ជាសកម្មជនសិទ្ធិមនុស្ស ជាអ្នកលក់សំលៀកបំពាក់សម្រាប់អ្នកស្រលាញ់ភេទដូចគ្នា និងជាបុគ្គលិកកិច្ចការសង្គមសម្រាប់ក្រុមប្រឹក្សាឃុំដែរ។ ពួកគាត់ទាំងពីរចូលចិត្តធ្វើដំណើរ និងចំណាយពេលនៅជាមួយគ្នា។

## អ្នកស្រី ហួរ និង ដែកគី លី



ដែកគី និងអ្នកស្រី ហួរ ជួបគ្នាតាមបណ្ដាញផ្សព្វផ្សាយសង្គម រឿងរ៉ាវស្នេហារបស់ពួកគាត់គឺពិតជារឿងមួយល្បីសុះសាយទូទាំងសាកលលោក។ ដែកគី ធ្វើការនៅក្នុងហាងធ្វើនំមួយនៅសហរដ្ឋអាមេរិក ហើយអ្នកស្រី ហួរ ក្រោយមកបានទៅរួមរស់នៅជាមួយគាត់ ក្រោយពីអ្នកទាំងពីរបានរៀបការនៅខែកុម្ភៈ ឆ្នាំ២០១៧។ ពួកគាត់ធ្វើពិធីរៀបអាពាហ៍ពិពាហ៍ដល់ទៅពីរដង គឺម្ដងជាពិធីបែបប្រពៃណីនៅក្នុងប្រទេសកម្ពុជា ហើយក្រោយមកពិធីផ្លូវការមួយទៀតនៅសហរដ្ឋអាមេរិក។ រូបថតនេះ បង្ហាញពីគូស្នេហ៍ ក្នុងទឹកមុខរីករាយនៅថ្ងៃមង្គលការតាមបែបប្រពៃណី។ ពួកគាត់រំភើបក្នុងចិត្តខ្លាំងណាស់ដោយមានវត្តមានរបស់ឪពុកម្ដាយ ញាតិសន្ដាន អ្នកជិតខាង និងមិត្តភក្ដិទាំងសងខាងមកចូលរួមក្នុងពិធីអាពាហ៍ពិពាហ៍របស់ពួកគាត់។

*សេចក្ដីស្រឡាញ់មិនស្គាល់ព្រំដែន ឬយេនឌ័រទេ។ នេះជារឿងខ្លះអំពីអ្នកស្រឡាញ់ភេទដូចគ្នាមួយចំនួន ដែលអង្គការ CamASEAN ជាដៃគូមួយរបស់អង្គការអុកស្វាម បានចងក្រងជាឯកសារ។ ដៃគូជាង១០០គូ បានបើកទ្វារស្វាគមន៍ឱ្យមានការចូលជួបដើម្បីកត់ត្រាសាច់រឿងរបស់ពួកគេសម្រាប់យកមករៀបចំធ្វើពិព័រណ៍រូបថតមួយ ដើម្បីផ្សព្វផ្សាយ និងកាត់បន្ថយការរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នា។*



## ស៊ុន ឡូន និង ទៀង សុខហៀង

ស៊ុន ឡូន និង ទៀង សុខហៀង មានអាយុជាង ៥០ឆ្នាំ ពួកគេបានរស់នៅជាមួយគ្នាអស់រយៈពេល ៣១ឆ្នាំហើយ នៅក្នុងភូមិស្ទង់ ខេត្តត្បូងឃ្មុំ។ ពួកគាត់លក់នំផ្អែមជិះកតាមកង់ លក់តាមភូមិ ដើម្បីលក់ឱ្យបានច្រើន។ នៅពេលដែល សុងហៀង ជួប ស៊ុន ឡូន ជាលើកដំបូង នាងមិនសូវទុកចិត្តគាត់ទេ ហើយក៏មិនអនុញ្ញាតឱ្យគាត់ទៅសួរសុខទុក្ខនាងដល់ផ្ទះដែរ។ ប៉ុន្តែ គុណសម្បត្តិរបស់ ស៊ុន ឡូន គឺនៅត្រង់ថាគាត់ពូកែអត់ធ្មត់ ហើយបន្តិចម្តងៗ គាត់ក៏ទទួលបានការទុកចិត្តពីសុខហៀង។



## យឺន ធី និង ណាវី

យឺន ធី មានអាយុ ៥៨ឆ្នាំ រីឯណាវី មានអាយុ ៦២ឆ្នាំ។ ទាំងពីរនាក់បានរស់នៅជាមួយគ្នាអស់ពេល ២៦ឆ្នាំមកហើយ។ ធី ជាអ្នកបើកម៉ូតូឌុប ហើយ ណាវី លក់សំលៀកបំពាក់។ ណាវី ធ្លាប់ធ្វើការនៅកន្លែងមួយទល់មុខនឹងក្រុមហ៊ុនមួយដែល ធី ធ្លាប់ធ្វើការដែរ ហើយតាមរយៈនេះហើយដែលពួកគេចាប់ផ្តើមជួបគ្នា។ អ្នកទាំងពីរចិញ្ចឹមកូនបីនាក់ ដែលណាវីមានពីមុន។



## ឈឹម ស៊ីម៉ុម និង ឈុន ម៉ុន

ស៊ីម៉ុម ធ្លាប់ធ្វើជាអ្នកបើកបរតាក់ស៊ីនៅពេលដែលគាត់ គ្រាមួយនោះ ស្រាប់តែជំពាក់ចិត្តស្រឡាញ់ ឈុន ម៉ុន។ អស់រយៈពេល ៣៧ឆ្នាំហើយ ដែលអ្នកទាំងពីរបានរស់នៅជាមួយគ្នាដោយឆ្លងកាត់ការប្រកបមុខរបរជាកម្មករសំណង់ ជាកម្មកររោងចក្រ ជាកសិករ និងជាអ្នកបើករ៉ឺម៉ក។ បច្ចុប្បន្ន អ្នកទាំងពីរបើកហាងលក់គ្រឿងទេសមួយនៅក្នុងខេត្តតាកែវ ហើយចិញ្ចឹមកូនពីរនាក់ម្នាក់ជាកូនស្រីដែល ឈុន ម៉ុន មានកាលពីចំណងស្នេហាពីមុន ហើយម្នាក់ទៀតជាកូនប្រុសដែលអ្នកទាំងពីរសុំគេយកមកចិញ្ចឹម។

*" យើងសូមថ្លែងអំណរគុណជាអនេកដល់គូស្នេហាទាំងអស់ដែលមានមោទនភាពឱ្យយើងបានថតរូប និងចែករំលែករឿងរ៉ាវដោយឥតលាក់លៀម។ "*

©All photos: CamASEAN



# រឿងរបស់យើង

## អនាគតថាមពលស្អាត

អង្គការអុកស្វាមប្រចាំនៅកម្ពុជាមានមោទនភាពណាស់ ដែលបានគាំទ្រថវិការ ដល់ការរៀបចំកម្មវិធី “សប្តាហ៍ថាមពលស្អាត” ជាលើកដំបូង ដែលរៀបចំឡើងដោយ Energy Lab រយៈពេលមួយអាទិត្យ នៅដើមខែវិច្ឆិកា ឆ្នាំ២០១៨ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងជុំវិញលទ្ធភាពរបស់ថាមពលកកើតឡើងវិញ ដោយមានការចូលរួមពីយុវជន និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

កញ្ញា យីង ស្រីពៅ ដែលដឹកនាំក្រុមអគ្គរាជទូតស្ម័គ្រចិត្ត១២នាក់ធ្វើការផ្សព្វផ្សាយនៅតាមសាកលវិទ្យាល័យ និយាយថា៖ “ក្នុងនាមជាអគ្គរាជទូតស្ម័គ្រចិត្ត យើងចង់ឃើញនិស្សិតទាំងអស់យល់ពីតម្រូវការចាំបាច់នៃថាមពលស្អាតក្នុងប្រទេសកម្ពុជា និងនៅទូទាំងពិភពលោក។ ខ្ញុំជឿថា នៅសាលារៀនពួកគេពិតជាធ្លាប់បានឮខ្លះហើយអំពីថាមពលស្អាត ប៉ុន្តែនៅមិនទាន់មានមនុស្សច្រើននាក់ទេដែលបង្ហាញចំណាប់អារម្មណ៍អំពីប្រធានបទនេះ។ ប្រហែលជាពួកគេគិតថាវាមិនមានសារៈសំខាន់ដូចជាវិស័យផ្សេងៗទៀត”។



អ្នកនាង Ol កំពុងបង្ហាញស្នប់សូឡាដែលយកតាមខ្លួនបានរបស់ EcoSun ទៅកាន់អ្នកចូលរួមក្នុងថ្ងៃដំបូងរបស់កម្មវិធី សប្តាហ៍ថាមពលស្អាត។ *©Bridget McIntosh*

### មនុស្សជាង ១២៥០នាក់ ចូលរួមកម្មវិធីថាមពលស្អាត!

សប្តាហ៍ព្រឹត្តិការណ៍ថាមពលស្អាត ត្រូវបានរៀបចំឡើង ដើម្បីឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធឱ្យបានច្រើន ដើម្បីលើកកម្ពស់ថាមពលស្អាតនៅក្នុងប្រទេសកម្ពុជា សម្រាប់ការអភិវឌ្ឍ ផលិតភាពសេដ្ឋកិច្ច និងនវានុវត្តន៍ប្រកបដោយចីរភាព។ សន្និសីទកម្រិតខ្ពស់មួយបានផ្តោតទៅលើអនាគតនៃថាមពលស្អាត ក្រោមប្រធានបទមានចំណងជើងថា “**ជំរុញស្មារតីអាស៊ាន**” ដោយប្រមូលតួអង្គសំខាន់ៗជាច្រើនក្នុងវិស័យថាមពលកកើតឡើងវិញក្នុងតំបន់អាស៊ីអាគ្នេយ៍ ឱ្យមកជួបជុំគ្នានៅទីក្រុងភ្នំពេញ ដោយមាននិស្សិតជាង ៦០០នាក់ចូលរួម សន្និសីទនេះរៀបចំឡើង ក្នុងគោលបំណងដាស់ស្មារតីយល់ដឹងរបស់សាធារណជនអំពីភាពចាំបាច់របស់ថាមពលស្អាតនៅថ្ងៃអនាគត។ សប្តាហ៍ថាមពលស្អាតជាលើកដំបូងនៅកម្ពុជា ជាកម្មវិធីជួបជុំដែលទទួលបានការចាប់អារម្មណ៍ពីមនុស្សជាច្រើន។

កម្មវិធីជាសារធារណៈជាច្រើនទៀតត្រូវបានរៀបចំធ្វើឡើងផងដែរ ដូចជាការចុះទស្សនកិច្ចដល់កន្លែងផ្ទាល់ និងឱកាសសម្រាប់ឱ្យភ្ញៀវចូលរួមបានឃើញផ្ទាល់នូវគំនិតផ្តួចផ្តើមនានា ដែលកំពុងអនុវត្តនៅក្នុងប្រទេសកម្ពុជា មានដូចជា ជីវឧស្ម័ន ការទាញយកថាមពលព្រះអាទិត្យ និងរោងចក្រផលិតធ្យូងមានចីរភាព ជាដើម។

កម្មវិធីបិទសប្តាហ៍ថាមពលស្អាតត្រូវបានប្រព្រឹត្តទៅនៅរោងចក្រភ្នំពេញ ដែលពេលនោះអ្នកចូលរួមបានអំពាវនាវទ្រហឹងអឹងកងឱ្យមានកម្មវិធីនេះជាលើកទីពីរទៀត។ អ្នកចូលរួមម្នាក់និយាថា៖ «សប្តាហ៍នេះពិតជាបាននាំមកនូវកម្លាំងចលករមួយ។ អស្ចារ្យណាស់! ខ្ញុំជឿថា កម្មវិធីឆ្នាំក្រោយនឹងកាន់តែមានសភាពខ្លាំងក្លានឹងជះឥទ្ធិពលកាន់តែខ្លាំងថែមទៀតជាមិនខាន!»

# សិទ្ធិទទួលបានដីធ្លីកាន់តែប្រសើរឡើង

អ្នកចូលរួមជាង ១០០នាក់ មកពីក្រុមរដ្ឋបាលថ្នាក់ក្រោមជាតិ រួមមានអភិបាលខេត្ត មន្ត្រីនគរបាល និងយោធា និង តំណាងអង្គការមិនមែនរដ្ឋាភិបាល បានមកជុំគ្នាក្នុងសិក្ខាសាលាមួយស្តីអំពី "ការធ្វើឱ្យប្រសើរឡើងនូវសិទ្ធទទួលបាន ដីធ្លី និងធនធានធម្មជាតិ និងការអនុវត្តច្បាប់" ដែលរៀបចំឡើងនៅចុងខែវិច្ឆិកាកន្លងទៅ ក្នុងខេត្តព្រះវិហារ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយអង្គការសិទ្ធិមនុស្សអាដហុក អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព (DPA) អង្គការអភិវឌ្ឍន៍សំឡេងសហគមន៍ (BCV) និងអង្គការអុកស្វាម ក្នុងគោលបំណងលើកកម្ពស់ចំណេះដឹងអំពី អភិបាលកិច្ចដីធ្លី បង្កើនកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរ និងសហគមន៍នៅក្នុងស្ថានភាពមានជម្លោះដីធ្លី និងផ្តល់ លទ្ធភាពឱ្យសហគមន៍ដែលពាក់ព័ន្ធ ចែករំលែកកង្វល់របស់ពួកគេជុំវិញជម្លោះនោះ ហើយស្វែងរកមធ្យោបាយល្អបំផុត ដើម្បីដោះស្រាយទាំងអស់គ្នា។

## ដីធ្លី គឺជាធនធានដ៏សំខាន់បំផុត សម្រាប់ប្រជាជនក្រីក្រ

ពីព្រោះវាផ្តល់មធ្យោបាយគន្លឹះសម្រាប់ពួកគេក្នុង ការបំពេញសេចក្តីត្រូវការផ្នែកស្បៀងអាហារ និង រកចំណូលសម្រាប់គ្រួសារ។

ឯកឧត្តម ស៊ូ ស៊ីរី អភិបាលរងខេត្តព្រះវិហារ មានប្រសាសន៍ ថា៖ "ប្រទេសកម្ពុជាមានច្បាប់ និងបទប្បញ្ញត្តិដែលគាំទ្រ ដល់សិទ្ធិដីធ្លី និងធនធានធម្មជាតិរបស់សហគមន៍ មូលដ្ឋាន។ ក្នុងពេលដែលពួកគេទទួលបានសិទ្ធិដីធ្លី និង ធនធានធម្មជាតិ ពួកគេក៏ត្រូវគោរពតាមនីតិរដ្ឋដែរ"។

វាគ្មិនមកពីតុលាការខេត្ត មន្ទីរជំនាញ និងអ្នកច្បាប់ បានចែករំលែកព័ត៌មានអំពីយន្តការដោះស្រាយទំនាស់ ដីធ្លីដែលត្រូវបានត្រៀមដាក់ឱ្យអនុវត្តនៅគ្រប់កម្រិត ទាំងអស់ ហើយវាគ្មិនបានលើកទឹកចិត្តឱ្យភាគីជម្លោះ ទាំងអស់ដាក់ពាក្យបណ្តឹងរបស់ពួកគេមកអាជ្ញាធរ មូលដ្ឋាន ដើម្បីគេអាចយកទៅចាត់ការបន្តទៀតឱ្យមាន ប្រសិទ្ធភាព។

បច្ចុប្បន្នមានករណីជម្លោះដីធ្លី និងធនធានធម្មជាតិ ៧ករណី ដែលត្រូវបានតំណាងសហគមន៍រាយការណ៍ នៅក្នុងសិក្ខាសាលាជូនជាព័ត៌មានដល់អាជ្ញាធរ ដើម្បី



អ្នកចូលរួមចែករំលែកអំពីករណីជម្លោះដីធ្លី។ *©Asisah Man/Oxfam*

ចាត់វិធានការអន្តរាគមន៍រកដំណោះស្រាយឱ្យបាន សមស្រប និងប្រកបដោយយុត្តិធម៌។ បើទោះជាពុំទាន់ មានករណីណាមួយត្រូវបានដោះស្រាយនៅក្នុងពេល សិក្ខាសាលានោះក៏ដោយ សេចក្តីរាយការណ៍នោះជា ជំហានធំមួយសម្រាប់ឱ្យភាគីពាក់ព័ន្ធទាំងអស់ពិចារណា ចាត់វិធានការបន្តទៀត ផ្អែកទៅតាមតួនាទី ភារកិច្ច និង អំណាចរៀងៗខ្លួន។

# ភាពក្រីក្រ និងវិសមភាពផ្នែកសេដ្ឋកិច្ច និងសង្គម

*តើវិធានការអ្វីខ្លះដែលរដ្ឋាភិបាលកម្ពុជាត្រូវប្រកាន់យកដើម្បីថា ប្រជាជនកម្ពុជាដែលងាយរងគ្រោះបំផុត មិនធ្លាក់ក្នុងភាពក្រីក្រវិញបាន? សំណួរនេះ និងសំណួរប្រហាក់ប្រហែលគ្នាផ្សេងទៀត ត្រូវបានលើកឡើង ក្នុងកិច្ចពិភាក្សាមួយស្តីពីអភិបាលកិច្ច និងគណនេយ្យភាពរបស់កម្ពុជា ក្នុងវេទិកាផ្លាស់ប្តូរយោបល់ (Forum of Exchanges) ដែលត្រូវបានរៀបចំឡើងនៅថ្ងៃទី២៦ ខែវិច្ឆិកា នៅទីក្រុងភ្នំពេញ។*

ប្រទេសកម្ពុជាមានកំណើនសេដ្ឋកិច្ចខ្ពស់ដែលគួរឱ្យកត់សម្គាល់ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ យោងតាមធនាគារពិភពលោក អត្រាកំណើនខ្ពស់នេះនៅមិនទាន់បានធ្វើឱ្យពលរដ្ឋកម្ពុជាទទួលបានផលស្មើគ្នានៅឡើយទេ ហើយបច្ចុប្បន្ន មានប្រជាជន ៤,៥លាននាក់ ដែលនៅតែរស់នៅក្នុងភាពក្រីក្រ ហើយងាយនឹងធ្លាក់ក្នុងភាពក្រីក្រតោកយ៉ាកណាស់ ក្នុងករណីមានស្ថានភាពមិនល្អ ឬមិនមានអំណោយផលណាមួយផ្នែកសេដ្ឋកិច្ច។ នេះជាស្ថានភាពពិតមួយ ជាពិសេសសម្រាប់ពលករក្រៅប្រព័ន្ធ ដែលមិនទាន់ត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធសុខាភិបាលសាធារណៈ និងការធានារ៉ាប់រងផ្នែកសន្តិសុខ និងជំនួយសង្គម។

## វេទិកាផ្លាស់ប្តូរយោបល់លើកឡើងបញ្ហាសំខាន់មួយចំនួន

កិច្ចពិភាក្សាក្នុងវេទិកានេះ បានផ្តោតលើបញ្ហានៃការកើនឡើងនូវវិសមភាពក្នុងប្រទេសកម្ពុជា បើទោះជាមានលំនឹងកំណើនសេដ្ឋកិច្ចខ្ពស់ក៏ដោយ។ វាគ្មិនបានសង្កត់ធ្ងន់លើភាពចាំបាច់ដែលរដ្ឋាភិបាលកម្ពុជាបង្កើត និងពង្រឹងសំណាញ់សុវត្ថិភាពឱ្យបានកាន់តែរឹងមាំ និងគ្រប់ជ្រុងជ្រោយថែមទៀត ដើម្បីការពារពលករ ជាពិសេសអ្នកទាំងឡាយដែលប្រកបរបរក្រៅប្រព័ន្ធ។



វេទិកាពិក្សាអំពីបញ្ហាវិសមភាពផ្នែកសេដ្ឋកិច្ច និងសង្គម។ ©Oxfam

អ្នកស្រី លឹម សូលីន នាយិកាអង្គការអុកស្វាមនៅកម្ពុជា ជាអ្នកសម្របសម្រួលវេទិកាវាគ្មិននេះ។ អ្នកឯកទេសផ្នែកអភិវឌ្ឍន៍ និងអភិបាលកិច្ចតំណាងបួនស្ថាប័ននៅកម្ពុជាក៏បានចែករំលែកបទពិសោធន៍ និងឯកទេសរបស់ពួកគេនៅលើប្រធានបទនេះផងដែរ។

វាគ្មិនក៏បានពិភាក្សាអំពីការរីកចម្រើនគួរឱ្យកត់សម្គាល់របស់រាជរដ្ឋាភិបាលក្នុងប៉ុន្មានឆ្នាំកន្លងមកនេះ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងផ្តល់សេវាសង្គម ដូចជាការធានារ៉ាប់រងសុខភាព និងការអប់រំ ប៉ុន្តែនៅមានកង្វះខាតជាក់ស្តែងសំខាន់ៗមួយចំនួនទៀតដែលចាំបាច់សម្រាប់ធ្វើឱ្យប្រព័ន្ធនោះដំណើរការឱ្យបានពេញទំហឹង។ ក្នុងនោះ វាគ្មិនបានចង្អុលទៅលើភាពពុករលួយ គណនេយ្យភាពនៅមានកម្រិត និងកង្វះជំនាញក្នុងចំណោមមន្ត្រីរាជការ។ ចំណុចទាំងនេះស្ថិតក្នុងចំណោមដើមហេតុធំៗមួយចំនួនដែលធ្វើឱ្យការផ្តល់សេវាសង្គមនៅមានកម្រិត និងមិនទាន់ជាទីពេញចិត្តដល់ពលករ និងពលរដ្ឋទូទៅ។

កិច្ចពិភាក្សានេះ ទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុពីអគ្គនាយកដ្ឋានសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងជំនួយមនុស្សធម៌របស់ប្រទេសប៊ែលហ្ស៊ិក ហើយវាក៏ជាផ្នែកមួយនៃកម្មវិធីសន្ទនារបស់ឯកអគ្គរដ្ឋទូតប៊ែលហ្ស៊ិក គឺឯកឧត្តម Philippe Kridelka ជាមួយសមាជិករបស់ក្របខណ្ឌយុទ្ធសាស្ត្ររួមរបស់កម្ពុជា (JFS) ដែរ។

# គាំទ្រកសិករស្ត្រីកសាងភាពជឿជាក់លើខ្លួនឯង

*គម្រោង “លើកកម្ពស់យេនឌ័រ និងការវិនិយោគប្រកបដោយការទទួលខុសត្រូវលើវិស័យកសិកម្ម នៅតំបន់អាស៊ីអាគ្នេយ៍” ហៅកាត់ GRAISEA គឺជាកម្មវិធីមួយដ៏សំខាន់របស់អង្គការអុកស្វាម ដែលគាំទ្រដល់កសិករឱ្យទទួលបានជំនាញ និងកសាងភាពជឿជាក់លើខ្លួនឯង ដើម្បីឈានទៅសម្រេចសក្តានុពលរបស់ខ្លួនជាអ្នកដឹកនាំ។*

“ខ្ញុំអានអក្សរខ្មែរមិនបានល្អ ប៉ុន្តែខ្ញុំនឹងខិតខំឱ្យអស់លទ្ធភាព”។ ក្រុមការងារយើងតែងតែឮស្ត្រីនិយាយដូច្នេះ នៅពេលណា យើងជួបពួកគាត់នៅទីជនបទ ទោះជាពួកគាត់កំពុងកាន់ការងារទទួលខុសត្រូវនៅក្នុងសហគមន៍របស់ខ្លួនក៏ដោយ។ ពួកគាត់មានសមត្ថភាព មានទឹកចិត្ត ហើយរៀនឆាប់ចេះ។ ប៉ុន្តែ ភាពជឿជាក់លើខ្លួនឯងរបស់ពួកគាត់ តែងតែស្ថិតក្រោមឥទ្ធិពលរបស់ផ្នត់គំនិតសង្គម និងពេលខ្លះឥទ្ធិពលរបស់ក្រុមគ្រួសារ និងមនុស្សនៅជុំវិញខ្លួន ដែលតែងនិយាយថាពួកគាត់មិនទាន់បានបញ្ចប់ការអប់រំផ្លូវការ ឬចប់បឋមសិក្សានៅឡើយទេ។

## ឧបសគ្គ និងសេចក្តីត្រូវការ

ពេលវេលាដែលស្ត្រីត្រូវចំណាយម្តងៗទៅលើកិច្ចការក្នុងផ្ទះ និងការថែទាំគ្រួសារ គឺជាកត្តាធំមួយប៉ះពាល់ទៅលើលទ្ធភាពរបស់ពួកគាត់ក្នុងការយកចិត្តទុកដាក់ដល់កិច្ចការសហគមន៍របស់ខ្លួន។ ភាគច្រើនលើសលុបពួកគាត់បានបញ្ចេញអារម្មណ៍របស់ខ្លួនឱ្យគេបានដឹងថាកម្រិតអប់រំទាប និងកង្វះជំនាញជាក់លាក់មួយចំនួន គឺជាមូលហេតុរារាំងពួកគាត់ក្នុងការសម្រេចបានអ្វីមួយដែលដែលពួកគាត់អាចធ្វើបានច្រើនជាងនេះ។ ពួកគាត់បានស្នើឱ្យមានការឧបត្ថម្ភគាំទ្រដល់ស្ត្រីឱ្យទទួលបានជំនាញដែលអ្នករស់នៅទីក្រុងភាគច្រើនមាន ដូចជាជំនាញប្រើកុំព្យូទ័រ របៀបកត់ត្រាកិច្ចប្រជុំ និងរបៀបរៀបចំបទបង្ហាញ ជាដើម។

ដោយមានមូលនិធិគាំទ្រពីស្ថានទូតប្រទេសស៊ុយអែតប្រចាំនៅទីក្រុងបាងកក ក្រុមហ៊ុន Sano Rice នៅប្រទេសហូលឡង់ និងក្រុមហ៊ុន Axfood នៅប្រទេសស៊ុយអែត តាមរយៈកិច្ចសហប្រតិបត្តិការជាមួយអង្គការអុកស្វាម និងអង្គការអភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាព ដែលជាដៃគូរបស់អុកស្វាម យើងនឹងធ្វើការកំណត់អត្តសញ្ញាណ និងជ្រើសរើសស្ត្រីអ្នកដឹកនាំបច្ចុប្បន្ន និងជាកសិករដែលចង់ស្វែងយល់អំពីសក្តានុពលភាពជាអ្នកដឹកនាំ ចំនួន៣៥នាក់ យកមកបណ្តុះបណ្តាលកសាងសមត្ថភាព។

មុននឹងឈានទៅបញ្ចប់គម្រោងនេះ យើងសង្ឃឹមថាគម្រោងនេះនឹងបានរួមចំណែកជួយដល់ថ្នាក់ដឹកនាំស្ត្រីជំនាន់ថ្មី ដែលប្រាថ្នាដឹកនាំសហគមន៍របស់ខ្លួនឆ្ពោះទៅកាន់ភាពរីកចម្រើន ជាមួយនឹងភាពជឿជាក់លើខ្លួនឯង និងក្តីសង្ឃឹមសម្រាប់អនាគត។

ខាត់ សុឃីម ហិរញ្ញិករបស់សហគមន៍កសិកម្មរណសិរ្សព្រះខ័នអភិវឌ្ឍន៍ នៅស្រុកសង្គមថ្មី ធ្វើបទបង្ហាញនិងពន្យល់ច្បាស់ៗអំពីអ្វីដែលគួរធ្វើ និងមិនគួរធ្វើក្នុងការដាំស្រូវសរីរាង្គ។ ©Oxfam






ប៊ុន សុគាយុគ (កណ្ដាល) និងសមាជិកក្រុម
ពេលកំពុងជជែកពិភាក្សា។ ©TI

# យុវជនពិភាក្សាដេញដោលអំពីអភិបាលកិច្ចសារពើពន្ធ

តើពលរដ្ឋគួរមានសិទ្ធិបញ្ចេញមតិរបស់ខ្លួននៅក្នុងសេចក្ដីព្រាងថវិកាឬទេ? តើរដ្ឋាភិបាលគួរបង្កើនពន្ធលើប្រាក់ចំណូលទេ? តើរដ្ឋាភិបាលគួរបង្កើនការលើកលែងពន្ធលើការវិនិយោគបរទេសទេ? សំណួរទាំងនេះ និងប្រធានបទផ្សេងៗទៀតជុំវិញអភិបាលកិច្ចសារពើពន្ធត្រូវបានយុវជន ៣២ក្រុម លើកយកពិភាក្សាដេញដោលគ្នាកាលពីខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៨។

ការពិភាក្សាដេញដោលនេះត្រូវបានរៀបចំឡើងដោយអង្គការតម្លាភាពអន្តរជាតិកម្ពុជា ដោយសហការជាមួយអង្គការអុកស្វាម ដើម្បីផ្ដល់លទ្ធភាពឱ្យយុវជនកសាងសមត្ថភាពរបស់ខ្លួន បង្កើតវប្បធម៌នៃការជជែកពិភាក្សា និងរៀនសូត្រពីគ្នាទៅវិញទៅមកលើប្រធានបទផ្សេងៗទាក់ទងនឹងអភិបាលកិច្ចសារពើពន្ធ។ **ប៊ុន សុគាយុគ** និស្សិតមកពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច ដែលជាអ្នកចូលរួមម្នាក់ដែរ និយាយថា៖ «នេះជាលើកទីមួយហើយសម្រាប់ខ្ញុំ ហើយខ្ញុំក៏មិនសូវយល់ពីប្រធានបទទាក់ទងនឹងអភិបាលកិច្ចសារពើពន្ធប៉ុន្មានដែរទេ។ ការពិភាក្សាដេញដោលនេះជួយខ្ញុំឱ្យចេះស្រាវជ្រាវថែមទៀត ជជែកជាមួយមនុស្សឱ្យបានច្រើន សួរសំណួរឱ្យច្រើន និងជម្រុញសមាជិកក្រុមរបស់ខ្ញុំឱ្យត្រៀមខ្លួនបានល្អដើម្បីពិភាក្សា និងផ្ដល់យោបល់ជាមួយក្រុមផ្សេងទៀត។»

## បង្កើតធនធានផ្នែកហិរញ្ញវត្ថុដើម្បីការអភិវឌ្ឍ

ជាពលរដ្ឋ យើងមិនត្រឹមតែមានភារកិច្ចឈ្វេងយល់អំពីថវិកាជាតិទេ ប៉ុន្តែក៏ត្រូវមានភារកិច្ចផងដែរក្នុងការធ្វើយ៉ាងណាឱ្យថវិកាជាតិពិតជាបម្រើប្រយោជន៍របស់ប្រជាជន។ ការពិភាក្សាដេញដោលរបស់យុវជនលើបញ្ហាទាំងនេះ គឺពិតជាចំណុចចាប់ផ្ដើមល្អមួយ។ លោក ព្រាប កុល នាយកប្រតិបត្តិរបស់តម្លាអន្តរជាតិកម្ពុជា និយាយថា ថវិកាជាតិមានសារៈសំខាន់ជាសារវន្តសម្រាប់ការអភិវឌ្ឍជាតិ សុខុមាលភាពរបស់ពលរដ្ឋ និងសម្រាប់អាទិភាពនៃការអភិវឌ្ឍជាតិ។

អង្គការអុកស្វាមបាននឹងកំពុងអនុវត្តគម្រោង "បង្កើតធនធានផ្នែកហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ" តាំងពីឆ្នាំ២០១៦ ដែលក្នុងនោះអង្គការតម្លាភាពអន្តរជាតិកម្ពុជាជាដៃគូមួយរបស់យើង។ គោលបំណងរបស់កម្មវិធីនេះ គឺដើម្បីលើកកម្ពស់គុណភាព និងបរិមាណនៃប្រព័ន្ធសារពើពន្ធនៅ កម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើង ដើម្បីជាប្រយោជន៍របស់ពលរដ្ឋ ជាពិសេសយុវជន ស្ត្រី ក្មេងស្រី និងពលរដ្ឋងាយរងគ្រោះ។

ប៊ុន សុគាយុគ និយាយថា៖ "តាមរយៈដំណើរការត្រៀមពិភាក្សាទាំងអស់នេះ ខ្ញុំកសាងទំនុកចិត្តលើខ្លួនឯង និងវិធីសាស្ត្រមានប្រសិទ្ធភាព។ ខ្ញុំរៀនសូត្របានថា ខ្ញុំត្រូវតែត្រៀមខ្លួនជាស្រេច ដើម្បីមានអំណះអំណាងការពារអ្វីដែលខ្ញុំនិយាយ។ ដើម្បីសម្រេចបានគោលបំណងនេះ ខ្ញុំចាំបាច់ត្រូវតែអានឱ្យច្រើន។ ខ្ញុំ ចង់ឃើញវេទិកាបែបនេះឱ្យបានច្រើនថែមទៀតសម្រាប់យុវជន"។

# ស្រ្តីដែលត្រូវបានមើលរំលង

*សោភ័ណ ជាអ្នកធ្វើការតាមផ្ទះ និងជាម្តាយមានកូនបីនាក់។ កាលពីពេលថ្មីៗនេះ នាងទើបសម្រាលបានកូនទីបីប្រកបដោយសុខភាពល្អ ប៉ុន្តែជីវភាពដ៏សែនលំបាករបស់នាងបានធ្វើឱ្យនាងស្ថិតក្នុងស្ថានភាពកាន់តែងាយរងគ្រោះថែមទៀត នៅពេលមួយដែលនាងសមតែទទួលបានសេចក្តីរីករាយ។*

នាងជាអ្នករកចំណូលសំខាន់ជាងគេសម្រាប់គ្រួសារ។ ប្តីរបស់នាងជាអ្នកលាងម៉ូតូលក្ខណៈគ្រួសារតូចមួយ ហើយគាត់អាចផ្តល់ឱ្យនាងបានតែ ៥០ដុល្លារ ទេក្នុងមួយខែ។ ការងារតាមផ្ទះ គឺជាកិច្ចការហត់នឿយណាស់សម្រាប់រាងកាយ។ នៅពេលដែលនាងជិតគ្រប់ខែ សោភ័ណ រងនូវការចុកចាប់ខ្លាំងទ្រាំមិនបាន ដែលអាចបណ្តាលឱ្យកូនក្នុងផ្ទៃពោះមានគ្រោះថ្នាក់។ ដោយស្តាប់តាមឱវាទរបស់ម្តាយ នាងក៏ឈប់ធ្វើការនៅពេលដែលគភ៌បាន៨ខែ។ ប៉ុន្តែ នៅពេលដែលគ្មានចំណូល នាងមិនមានលទ្ធភាពក្នុងការចំណាយទៅលើថ្លៃម្ហូប ថ្លៃផ្ទះ និងថ្លៃពេទ្យនោះទេ។ ដូច្នេះ សោភ័ណ ក៏សម្រេចចិត្តវិលទៅនៅផ្ទះជាមួយម្តាយ ពឹងផ្អែកលើម្តាយឱ្យជួយ ម្តាយសោភ័ណក៏ជាអ្នកធ្វើការតាមផ្ទះដែរ។

ក្រោយពេលដែលបានដឹងថាសោភ័ណមិនអាចធ្វើការបាន ហើយគ្មានប្រាក់សន្សំទេ ម្តាយរបស់នាងក៏ទៅខ្ចីប្រាក់ពីមេរបស់គាត់ សម្រាប់យកមកចំណាយលើថ្លៃសម្រាលកូនរបស់សោភ័ណ នៅមន្ទីរពេទ្យមួយក្នុងទីក្រុងភ្នំពេញ។ ជាអកុសល នៅជិតថ្ងៃសម្រាលកូនមកដល់ ស្រាប់តែម្តាយរបស់សោភ័ណរងរបួសនៅកន្លែងធ្វើការ ហើយមិនអាចធ្វើការតទៅទៀតបានអស់ជាច្រើនខែព្រោះត្រូវសម្រាកព្យាបាលរបួស។ ក្រោយពីនាងសម្រាលកូនរួច សោភ័ណ ត្រូវមើលថែទាំម្តាយ ដែលមានរបួសផង និងកូនខ្ចីរបស់ខ្លួនផង និងត្រូវសងប្រាក់ខ្ចីគេផង។ ជាមួយនឹងសេចក្តីត្រូវការច្រើនបែបនេះ សោភ័ណ ត្រូវបង្ខំចិត្តត្រឡប់ទៅធ្វើការវិញមុនកាលកំណត់ ទាំងមិនដឹងថាតើត្រូវថែទាំកូន និងម្តាយដោយរបៀបណា ឬក៏ថានឹងមានអ្នកណាជួយឡើយ។

នៅពេលដែលនាងមិនបានទៅធ្វើការកាន់តែយូរ គ្រួសាររបស់នាងទាំងមូលធ្លាក់ខ្លួនកាន់តែក្រ។

## រឿងរ៉ាវដូចជារឿងរបស់ សោភ័ណ កើតមាននៅកម្ពុជា ជារៀងរាល់ថ្ងៃ

យោងតាមរបាយការណ៍របស់អង្គការអន្តរជាតិខាងការងារ ILO នារីពលករក្រៅប្រព័ន្ធ ៧៧% យល់ថាខ្លួនប្រឈមភាពរងគ្រោះខ្ពស់ណាស់នៅពេលណាដែលពួកគេត្រូវនៅថែទាំទារកទើបនឹងកើត និងត្រូវសម្រាកក្នុងពេលបែបនេះក្នុងជីវិតរបស់គេ។

រឿងរ៉ាវទាំងនេះគូសរំលេចឱ្យឃើញនូវគម្លាតកាន់តែធំឡើងរវាងអ្នកមាន និងអ្នកក្រនៅកម្ពុជា ហើយជាអកុសលគម្លាតនេះកំពុងតែបំផ្លាញដល់កិច្ចខិតខំនានាកន្លងមកក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនៅក្នុងប្រទេសនេះ។ កម្ពុជាមិនមែនជាករណីដាច់ដោយឡែកនោះទេ។ នៅទូទាំងពិភពលោក វិសមភាពបាននឹងកំពុងតែកើនខ្ពស់ឡើង ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។

រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការសំខាន់ៗជាច្រើនឆ្ពោះទៅផ្តល់ការថែទាំសុខភាពដល់ពលរដ្ឋច្រើនថែមទៀត តាមរយៈការដាក់ឱ្យប្រើកាតថែទាំសុខភាព (HEC) និងបេឡាជាតិរបបសន្តិសុខសង្គម (NSSF)។ ប្រព័ន្ធទាំងពីរនេះជាជំហានដ៏សំខាន់ឆ្ពោះទៅពង្រីកការគ្របដណ្តប់សេវាថែទាំសុខភាព ប៉ុន្តែមានចំណុចច្រើនទៀតដែលត្រូវធ្វើឱ្យកាន់តែប្រសើរ។ ការវិនិយោគច្រើនទៀតលើផ្នែកនេះ គឺជាភាពចាំបាច់ដើម្បីពង្រីកវិសាលភាពគ្របដណ្តប់របស់សេវា និងធ្វើឱ្យគុណភាពរបស់សេវាកាន់តែមានភាពប្រសើរឡើង។



សោភ័ណ និងកូន ©Oxfam

# ទស្សនវិស័យ

ការប្តេជ្ញាចិត្តឆ្នាំ2019



## ឯកឧត្តម GEORGE EDGAR

ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា

នៅក្នុងឆ្នាំ២០១៩ យើងនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាលកម្ពុជា និងដៃគូសង្គមស៊ីវិល ឆ្ពោះទៅអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) នៅកម្ពុជា។ SDGs ជាក្របខណ្ឌសម្រាប់អ្វីៗគ្រប់បែបយ៉ាងដែលយើងធ្វើនៅកម្ពុជា។ យើងមានបំណងចង់ធ្វើយ៉ាងណាឱ្យកម្ពុជាទទួលបានកំណត់ត្រាល្អនៅក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដូចគ្នានឹងកំណត់ត្រាដែលប្រទេសនេះទទួលបាននៅក្នុងការសម្រេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កន្លងមកដែរ។

និយាយឱ្យទូលាយបន្តិច អ្វីដែលសំខាន់ខ្លាំងក្នុងចំណោមរឿងសំខាន់នានាសម្រាប់ឆ្នាំនេះ គឺយើងទាំងអស់ធ្វើយ៉ាងណាត្រូវប្រកាន់ភាពម៉ឺងម៉ាត់ជាមួយបញ្ហាប្រឈម ការគំរាមកំហែង និងវិបត្តិបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ហើយយកវាមកឆ្លុះបញ្ចាំងនៅតាមគ្រប់វិធីដែលយើងឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនោះ។ នៅកម្រិតសាកល យើងក៏ត្រូវតែបង្កើនមហិច្ឆតារបស់យើងឱ្យកាន់តែមានកម្រិតខ្លាំងឡើងថែមទៀតដែរ។

សហភាពអឺរ៉ុបឧបត្ថម្ភគាំទ្រដល់កម្មវិធីធំមួយស្តីពីកំណែទម្រង់វិស័យអប់រំ ដោយផ្តោតសំខាន់ទៅលើការអប់រំមុនកម្រិតបឋមសិក្សា ក្នុងកម្រិតបឋមសិក្សា និងក្នុងកម្រិតមធ្យមសិក្សាចំណេះទូទៅ។ សហភាពអឺរ៉ុបក៏នឹងបន្តគាំទ្រទៀតដែរ ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីធានាយ៉ាងណាឱ្យមានភាពកាន់តែប្រសើរនៅក្នុងការប្រមូលចំណូល និងចំណាយក្នុងស្រុកដែលបម្រើប្រកបដោយប្រសិទ្ធភាពដល់សេចក្តីត្រូវការរបស់ប្រជាជន។

បច្ចុប្បន្ននេះ សហភាពអឺរ៉ុបកំពុងស្ថិតក្នុងដំណើរការសម្ភោធដំណាក់កាលថ្មីមួយទៀតនៃការចូលពាក់ព័ន្ធផ្តល់ការឧបត្ថម្ភគាំទ្រដល់វិស័យនេសាទ ទាំងផ្នែកវារីវប្បកម្ម ដែលកម្ពុជានៅមានសក្តានុពលធំ និងផ្នែកនេសាទត្រី។ វាជារឿងសំខាន់ដែលត្រូវធានាយ៉ាងណាឱ្យវិស័យជលផលនេះរួមចំណែកមានប្រសិទ្ធភាពដល់ការចិញ្ចឹមជីវិតរបស់ប្រជាជន និងដល់អាហារូបត្ថម្ភនៅកម្ពុជា។ ប៉ុន្តែ វាក៏មានសារៈសំខាន់ស្មើគ្នាដែរ ដែលគេត្រូវផ្តោតទៅលើការអភិរក្សធនធាន ដើម្បីធានាយ៉ាងណាកុំឱ្យវាត្រូវបានគេទាញយកទៅប្រើប្រាស់លើសសមត្ថភាព ឬរងការបំផ្លិចបំផ្លាញដោយសារតែសកម្មភាពអភិវឌ្ឍន៍នៅតាមតំបន់ជុំវិញទន្លេ និងបឹង។

យើងតែងតែរៀនសូត្រមេរៀនជាច្រើន អំពីរបៀបធ្វើដូចម្តេចឱ្យបានប្រសើរជាងមុន តាមរយៈការធ្វើការដោយផ្ទាល់ជាមួយរដ្ឋាភិបាល និងសង្គមស៊ីវិល។ ខ្ញុំសូមជូនពរមិត្តអ្នកអាន “ពីនេះពីនោះ” ឱ្យទទួលបានតែសុភមង្គល ជោគជ័យ និងវិបុលសុខ នៅក្នុងឆ្នាំ២០១៩នេះ។

*យើងតែងតែរៀនសូត្រមេរៀនជាច្រើន អំពីរបៀបធ្វើការឱ្យបានប្រសើរជាងមុន តាមរយៈការធ្វើការដោយផ្ទាល់ជាមួយរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។ ខ្ញុំសូមជូនពរមិត្តអ្នកអាន "ពីនេះពីនោះ" ឱ្យទទួលបានតែសុភមង្គល ជោគជ័យ និងវិបុលសុខ នៅក្នុងឆ្នាំ២០១៩នេះ។*



## លោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី

រដ្ឋមន្ត្រីនៃក្រសួងកិច្ចការនារី

*"ក្នុងឆ្នាំ២០១៩នេះ ក្រសួងកិច្ចការនារីមានគោលដៅបន្តពង្រឹងកិច្ចអភិវឌ្ឍន៍ធនធានមនុស្សជាស្ត្រី និងធានាចំពោះការផ្តល់ភាពអង់អាចដល់ស្ត្រីលើផ្នែកសេដ្ឋកិច្ច។"*

អាណត្តិថ្មីនេះ ក្រសួងកិច្ចការនារីនឹងបន្តពង្រឹងសមត្ថភាពក្នុងភាពជាអ្នកដឹកនាំដល់ស្ត្រី ទាំងក្នុងវិស័យនយោបាយ សង្គម និងវិស័យសេដ្ឋកិច្ចទាំងនៅក្នុងប្រទេស និងថ្នាក់តំបន់។ ដើម្បីឆ្លើយតបទៅនឹងសកលភាវូបនីយកម្ម ក្រសួងកិច្ចការនារីនឹងយកចិត្តទុកដាក់ទៅលើការកសាងសមត្ថភាពធនធានមនុស្ស ជាពិសេសស្ត្រី ដើម្បីចូលរួមប្រកួតប្រជែង និងប្រកបដោយនវានុវត្តន៍ក្នុងទីផ្សារការងារ ក៏ដូចជាបង្កើនសមត្ថភាពរបស់ពួកគេដើម្បីសម្របខ្លួនទៅនឹងការផ្លាស់ប្តូរ និងការសិក្សា ដើម្បីក្លាយទៅជាសហគ្រិន និងបុគ្គលិកដ៏ជោគជ័យដើម្បីរក្សាកំណើនសេដ្ឋកិច្ចកម្ពុជា។

ដូចគ្នានេះផងដែរ ពួកយើងនឹងបន្តយកចិត្តទុកដាក់លើការបង្កើនសក្តានុពលសេដ្ឋកិច្ចចំពោះស្ត្រីដើម្បីរួមចំណែកកាត់បន្ថយភាពងាយរងគ្រោះរបស់ពួកគេ និងពង្រឹងភាពអង់អាចរបស់ស្ត្រីក្នុងតួនាទីជាដៃគូដ៏មានតម្លៃជាមួយបុរសក្នុងសង្គម។ ដើម្បីអនុវត្តផែនការនេះ ក្រសួងសហការជាមួយក្រសួងពាក់ព័ន្ធដើម្បីបន្តអប់រំ និងផ្សព្វផ្សាយព័ត៌មានដល់ស្ត្រីពាក់ព័ន្ធនឹងច្បាប់ ដូចជាច្បាប់ការងារ ដើម្បីការពារសិទ្ធិរបស់ពួកគេ រួមទាំងបន្តអនុវត្តសកម្មភាពលើកកម្ពស់ជីវភាពរស់នៅរបស់បងប្អូនស្ត្រី នៅតាមជនបទឱ្យមានជំនាញវិជ្ជាជីវៈ ដើម្បីប្រកបមុខរបរកសិកម្មក៏ដោយមិនកសិកម្មក៏ដោយ ឱ្យស៊ីសង្វាក់ទៅនឹងតម្រូវការទីផ្សារសម្រាប់ផលិតផល និងអាជីវកម្មរបស់ពួកគេ។

ដើម្បីលើកកម្ពស់សុខុមាលភាពស្ត្រី និងកុមារ ក្រសួងចូលរួមជាមួយនឹងក្រសួងពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា ពោលគឺគោលនយោបាយគាំពារសង្គម ដើម្បីធានាថា "**មិនទុកនរណាម្នាក់ឱ្យនៅឯកោ**" ហើយធានាថា ស្ត្រី ស្ត្រីមានផ្ទៃពោះ ក្មេងស្រី និងក្រុមងាយរងគ្រោះ ទទួលបានអត្ថប្រយោជន៍ពីកំណើនសេដ្ឋកិច្ចដ៏រឹងមាំរបស់ប្រទេសជាតិយើង។

ដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី និងកុមារ ក្រសួងកិច្ចការនារីសហការជាមួយក្រសួងពាក់ព័ន្ធនឹងបន្តពង្រឹងការអនុវត្តផែនការស្តីពី ការទប់ស្កាត់រាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និងក្មេងស្រី ២០១៩-២០២៣ និងលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ។ យើងនឹងយកចិត្តទុកដាក់ខ្ពស់ ចំពោះសង្គម និងការអប់រំមូលដ្ឋាន ក្នុងគោលដៅដើម្បីផ្លាស់ប្តូរផ្នត់គំនិតសង្គមដោយប្រឆាំងនឹងការរើសអើងចំពោះស្ត្រីភេទ ការទទួលខុសត្រូវខ្ពស់នៃការពិសារគ្រឿងស្រវឹង និងបង្រ្កាបការប្រើប្រាស់គ្រឿងញៀន។ ក្រសួងនឹងពង្រីកការអនុវត្តកម្មវិធី "**អប់រំកូនតាមបែបវិជ្ជមាន**" រួមទាំងសហការជាមួយនឹងក្រុមគ្រួសារនៅគ្រប់មជ្ឈដ្ឋានដើម្បីអនុវត្តផែនការនេះ។ ចំពោះបញ្ហាអំពើហិង្សាក្នុងគ្រួសារ ពួកយើងនឹងបន្តពង្រឹងវប្បធម៌សន្ទនាដើម្បីដោះស្រាយជម្លោះ និងពង្រីកយុទ្ធនាការបុរសល្អ។ បញ្ហាមួយទៀតដែលយើងគួតែចាប់អារម្មណ៍ គឺឥរិយាបថយុវវ័យក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ពួកយើងនឹងបំផុសឱ្យយុវវ័យឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាឱ្យមានទំនួលខុសត្រូវខ្ពស់ដោយមិនប្រាសចាកពីទិសដៅនៃការអប់រំព័ត៌មាន និងចំណេះដឹង។



# ឌិម សារ៉ាត

នាយកប្រតិបត្តិ
អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០០ និងធ្វើការចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃ នៅខែធ្នូ ឆ្នាំ២០០៣ ដោយធ្វើការផ្តោតទៅលើវិស័យជលផល និងបរិស្ថាននៅជុំវិញបឹងទន្លេសាប ទន្លេមេគង្គ និងតំបន់ឆ្នេរនៃប្រទេសកម្ពុជា។ FACT ធ្វើការទាក់ទងការចងក្រង និងពង្រឹងសមត្ថភាពសហគមន៍នេសាទការតស៊ូមតិ និងតាមដានលើកំណែទម្រង់នៃគោលនយោបាយដែលទាក់ទងលើវិស័យជលផល។

ក្នុងឆ្នាំ២០១៩នេះ អង្គការ FACT នឹងបន្តអនុវត្តផែនការយុទ្ធសាស្ត្រប្រាំឆ្នាំ (២០១៥-២០១៩) របស់ខ្លួន ដោយប្តេជ្ញាចិត្តយ៉ាងមុតមាំ ដើម្បីឈានទៅសម្រេចឱ្យបាននូវសកម្មភាពសំខាន់ៗដូចខាងក្រោម៖

១. បន្តពង្រឹងអង្គការសហគមន៍មូលដ្ឋាន តាមរយៈការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ហើយជាពិសេសជម្រុញដល់អ្នកជំនាញថ្នាក់ជាតិទទួលស្គាល់អង្គការសហគមន៍មូលដ្ឋាន។

២. ពង្រឹងបណ្តាញជាមួយអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូ ដែលធ្វើការក្នុងវិស័យជលផល (បច្ចុប្បន្នមានអង្គការមិនមែនរដ្ឋាភិបាលចំនួន ៤៥)។

៣. ផ្តោតទៅលើសកម្មភាពផ្សព្វផ្សាយ និងការងារអភិរក្សរបស់ខ្លួន នៅលើទីតាំងចំនួន៨៤កន្លែង ជាមួយដៃគូពាក់ព័ន្ធ និងមានការគាំទ្រមូលនិធិពីសហភាពអឺរ៉ុប និងម្ចាស់ជំនួយនានាទៀត។

៤. ពង្រឹងអភិបាលកិច្ចល្អនៅក្នុងវិស័យជលផល ដើម្បីជម្រុញលើកទឹកចិត្តប្រជានេសាទ ឱ្យមានការទទួលខុសត្រូវកាន់តែច្រើនឡើង នៅក្នុងសហគមន៍នេសាទរបស់ខ្លួន។

៥. ធ្វើការបោះពុម្ពផ្សាយ ចែករំលែកករណីសិក្សាអំពីជលផល និងផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុ ក៏ដូចជាការបញ្ជ្រាបការបន្សាំការប្រែប្រួលអាកាសធាតុផងដែរ។

៦. ពង្រឹងសិទ្ធិអំណាចរបស់សហគមន៍មូលដ្ឋាន លើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល វគ្គអប់រំវិជ្ជាជីវៈតម្រង់ទិស ដូចជាការបង្កើតរមណីយដ្ឋានទេសចរណ៍ធម្មជាតិ ឬការបង្កើតមធ្យោបាយសម្រាប់ធានាដល់ការស្តុកទុកផលិតផលនេសាទបានយូរ។ គោលបំណងសំខាន់ គឺជួយដល់ប្រជានេសាទមូលដ្ឋានឱ្យកាត់បន្ថយការពឹងផ្អែកលើរបរនេសាទតែមួយមុខ។

៧. លើកកម្ពស់គុណភាពនៃផលិតផលនេសាទ ដោយគោរពតាមស្តង់ដាដែលមានការទទួលស្គាល់ត្រឹមត្រូវ។ សហគមន៍នេសាទមូលដ្ឋាននឹងទទួលបានការគាំទ្រ នៅពេលណាផលិតផលរបស់ពួកគេបំពេញបានតាមស្តង់ដា ដូច្នេះ ចំណូលរបស់ពួកគេក៏នឹងកើនទៅតាមនោះដែរ។

៨. ដោយផ្តោតទៅលើសមភាពយេនឌ័រ ធ្វើការពិភាក្សាអំពីការអភិវឌ្ឍសង្គមប្រកបដោយយុត្តិធម៌ត្រឹមត្រូវ និងមានចីរភាព នៅក្នុងគ្រប់គម្រោងទាំងអស់របស់យើង។

៩. លើកកម្ពស់សម្ព័ន្ធភាពផ្ទៃក្នុង ដោយពង្រឹងសមត្ថភាពបុគ្គលិក បង្កើតគណៈគ្រប់គ្រងមួយសម្រាប់សមាជិកក្រុម ហើយធ្វើការបង្កើន និងពង្រឹងសមត្ថភាពរបស់ក្រុមតាមដាន និងវាយតម្លៃហិរញ្ញវត្ថុ ដើម្បីធានាឱ្យមានតម្លាភាព និងភក្តីភាព។

*“ផែនការដាក់ស្តែងថ្មីរបស់យើងនឹងផ្តោតសំខាន់ទៅលើអភិបាលកិច្ចល្អ និងរបរចិញ្ចឹមជីវិត ការកែច្នៃផលនេសាទ និងខ្សែច្រវាក់ផលិតកម្មជលផល”។*



# សរ សាន

សហគ្រិនវ័យក្មេង

*"ខ្ញុំសូមជម្រុញលើកទឹកចិត្តឱ្យជនពិការគ្រប់រូបឱ្យក្រោកឈរឡើង ហើយមានមោទនភាពចំពោះជីវិតពិការភាពរបស់ខ្លួន ដោយប្រឹងប្រែងជម្នះរាល់ឧបសគ្គដែលខ្លួនជួបប្រទះ ត្រូវលើកទឹកចិត្ត និងផ្តល់តម្លៃឱ្យខ្លួនឯង មុននឹងឱ្យអ្នកដទៃជួយ និងឱ្យតម្លៃយើង។"*

លោកស្រី សរ សាន ញញឹមបណ្ដើរ រៀបរាប់បណ្ដើរពីក្រមា កាបូប និងបូរចងសក់ធ្វើដោយដៃ ដែលនៅតម្រៀបលើតុ នៅផ្ទះគាត់ឯកោះដាច់។ គាត់ប្រាប់ថា ទាំងអស់នេះសុទ្ធតែជាផលិតផលដែលគាត់ជួយដល់ស្ត្រីដែលមិនសូវទទួលបានការយកចិត្តទុកដាក់ និងស្ត្រីប្រកបមុខរបរក្រៅប្រព័ន្ធ ដើម្បីលក់រកប្រាក់ចំណូលបន្ថែមសម្រាប់ទ្រទ្រង់គ្រួសារ។

សាន បានចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនថា៖ “ទោះបីជាខ្ញុំពិការ តែខ្ញុំបានតស៊ូរៀនចប់ថ្នាក់បរិញ្ញាបត្របច្ចេកវិទ្យាព័ត៌មាន នៅសាកលវិទ្យាល័យអន្តរជាតិភ្នំពេញ។ សព្វថ្ងៃ ខ្ញុំជាមន្ត្រីផ្នែកអភិវឌ្ឍសេវាពិការភាពនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយគ្រួសារខ្ញុំជាមន្ត្រីផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ នៅក្រសួងជាមួយគ្នា។ ពេលទំនេរ ខ្ញុំជួយជនមានពិការភាពអតីតស្ត្រីបម្រើសេវាកំសាន្ត អ្នកស្រលាញ់ភេទដូចគ្នា និងស្ត្រីក្រីក្រ លក់ផលិតផលរបស់គាត់ និងផ្លែឈើក្នុងស្រុកមួយចំនួនសម្រាប់ប្រាក់ចំណូលពួកគាត់បន្ថែម និងចូលរួមសកម្មភាពការងារសប្បុរសធម៌ផងដែរ។

ខ្ញុំសប្បាយចិត្តក្នុងការរស់នៅជាមួយដៃគូប្រចាំជីវិតរបស់ខ្ញុំ ទោះគាត់ជិះតែលើរទេះមែន ប៉ុន្តែគាត់មានការតាំងចិត្តដូចខ្ញុំដែរក្នុងការជម្នះពិការភាព។”

សាន និយាយថា ឆ្នាំ២០១៨កន្លងទៅ គឺជាឆ្នាំពោលពេញទៅដោយផ្លែផ្កាសម្រាប់គាត់ ហើយអ្វីដែលគាត់ចង់បានក្នុងឆ្នាំ២០៩១ គឺពង្រីកមុខរបរដោយបន្ថែមមុខទំនិញឱ្យបានច្រើនមុខ ហើយបន្តជួយស្ត្រីក្រីក្រ ជាពិសេសក្រុមជនដែលមិនសូវទទួលបានការយកចិត្តទុកដាក់ តាមរយៈការយកផលិតផលរបស់ពួកគេទៅលក់នៅព្រឹត្តិការណ៍ពិព័រណ៍ជាតិ និងកម្មវិធីនានានៅក្នុងភូមិ។ “ខ្ញុំនឹងប្រឹងប្រែងបំពេញតាមលក្ខខណ្ឌតម្រូវរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីអាចឱ្យគេផ្តល់ឱកាសដល់ជនក្រីក្រមានពិការភាពដាក់បញ្ជូរលក់ដូរនៅក្នុងពិធីតាំងពិព័រណ៍ថ្នាក់ជាតិនានា។ ចុងក្រោយ គឺខ្ញុំប្រាថ្នាចង់ទិញឡានតូចមួយសម្រាប់ដឹកទំនិញឱ្យអតិថិជន។ បច្ចុប្បន្នខ្ញុំទៅណាមកណាបានដោយសារតែម៉ូតូកង់បីរបស់ខ្ញុំតែប៉ុណ្ណោះ។”

សូមកុំបោះបង់ការគិតរបស់ខ្លួន ដោយមិនទាន់ចាប់ផ្តើមសាកល្បង ត្រូវចាំថាអ្នកអាចដើរយឺតជាងគេមួយជំហ៊ាន តែថ្ងៃណាមួយអ្នកនឹងទៅដល់គោលដៅដូចគេដែរ។ ខ្ញុំសង្ឃឹមថា មិត្តមានពិការភាពដែលបានអានព្រឹត្តប័ត្រ “ពីនេះពីនោះ” នេះ ជួយជាកម្លាំងចិត្តដើរទៅមុខទាំងអស់គ្នា មិនត្រូវបោះបង់សុបិនរបស់ខ្លួនចោល ហើយប្រឹងជម្នះការលំបាកដើម្បីអនាគតរបស់ខ្លួន។ ជនមានពិការភាពមានជីវិតមួយ អ្នកធម្មតាមិនមានពិការភាពក៏មានជីវិតមួយដែរ។ ខ្ញុំក៏សង្ឃឹមដែរថាអ្នកឯទៀតប្រព្រឹត្តឱ្យបានគប្បីទៅលើជនពិការ ហើយផ្តល់ឱកាសឱ្យពួកគេបានទទួលការងារធ្វើដូចអ្នកឯងទៀតដែរ។"

# ព្រឹត្តិការណ៍ខាងមុខ

## ខែមីនា ២០១៩

### វគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាលបុគ្គលិកអង្គការអុកស្វាម និងដៃគូ ស្តីពីការត្រៀមធ្វើការឆ្លើយតបបន្ទាន់ក្នុងគ្រាអាសន្ន

## ខែមេសា ២០១៩

### វគ្គបង្រៀន

វគ្គបង្រៀនស្ត្រីក្នុងភាពជាអ្នកដឹកនាំក្នុងមូលដ្ឋាន

## ខែឧសភា ២០១៩

### វគ្គ

សប្តាហ៍មោទនភាព

# ព័ត៌មាន

## ស្វែងយល់សម្លេងប្រជាជនកម្ពុជា

ស្វែងយល់សម្លេងប្រជាជនកម្ពុជា ( Exploring Cambodian Voices ) គឺជាការវិភាគបរិបទស៊ីជម្រៅមួយសម្រាប់ "កម្មវិធីវ៉យ" នៅក្នុងប្រទេសកម្ពុជា ។ ក្នុងនោះមានការសំដែងមតិរបស់ជនមកពីក្រុមផ្សេងៗគ្នា រួមមានជនមានពិការភាព អ្នកស្រលាញ់ភេទដូចគ្នា ស្ត្រីដែលត្រូវបានគេកេងប្រវ័ញ្ច រងការបំពាន និងរងអំពើហិង្សា និងអ្នកប្រឈមនឹងការរើសអើង និងភាពងាយរងគ្រោះដោយសារតែកម្រិតអាយុ ក្រុមជនជាតិដើម និងក្រុមជនជាតិដើមភាគតិច ។

https://cambodia.oxfam.org/policy_paper/exploring-cambodian-voices







កម្មករក្រៅប្រព័ន្ធជាង២០០នាក់ បានមកជួបជុំគ្នាធ្វើការពិភាក្សាបញ្ហាស្តីពី "**ការងារគ្មានតម្រៃ**" ដូចជាការងារជាអ្នកថែទាំ និងផលប៉ះពាល់របស់វាទៅលើភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់អ្នកទាំងឡាយដែលផ្តល់ការថែទាំ និងលទ្ធភាពស្មើគ្នាសម្រាប់ស្ត្រីក្នុងការស្វែងរកទីផ្សារការងារធ្វើ ។

https://cambodia.oxfam.org/event/forum-practical-paths-reduce-gender-inequality

ហេតុអ្វីបានជាសំខាន់ត្រូវមានផែនការធុរកិច្ចឱ្យបានត្រឹមត្រូវជាមុន ? សូមចូលមើលវីឌីអូដែលមានរយៈពេល ៦នាទី ដើម្បីស្វែងយល់អំពីផលវិបាកក្នុងការស្វែងរកឥណទានដោយគ្មានផែនការច្បាស់លាស់ជាមុន ៖

https://www.youtube.com/watch?v=WShRXBGSiqU


©Vlad Sokhin/Panos/OxfamAUS

# អុកស្វាមនៅជុំវិញពិភពលោក

### ទីម័រខាងកើត

នៅប្រទេសទីម័រខាងកើត អង្គការអុកស្វាមកំពុងប្រើប្រាស់វិធីសាស្ត្រដែលដឹកនាំដោយសហគមន៍ ដើម្បីលើកកម្ពស់ការរស់នៅរបស់ស្ត្រី និងបុរសនៅតំបន់ជនបទ។ ក្រោមភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិលចំនួន២០ ស្ថាប័ន កំពុងធ្វើការលើកកម្ពស់សមភាព និងការការចិញ្ចឹមជីវិតប្រកបដោយភាពធន របស់កសិករខ្នាតតូច។



### សាធារណរដ្ឋដូមីនីក

នៅសាធារណរដ្ឋដូមីនីក អង្គការអុកស្វាមកំពុងធ្វើការលើកកម្ពស់សិទ្ធិរបស់បុរស និងស្ត្រីងាយរងគ្រោះបំផុត ដោយត្រៀមខ្លួនពួកគេឱ្យមានលទ្ធភាពប្រឈមជាមួយស្ថានភាពមានវិបត្តិ និង ដើម្បីអាចទទួលបានជំនួយមនុស្សធម៌មានគុណភាពខ្ពស់។

### តង់សានី

នៅប្រទេសតង់សានី អង្គការអុកស្វាមកំពុងធ្វើការពង្រឹងភាពអង់អាចរបស់ស្ត្រីផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីប្រែក្លាយខ្លួនជាអ្នកដឹកនាំ និងជាភ្នាក់ងារផ្លាស់ប្តូរនៅក្នុងគ្រួសារ និងសហគមន៍របស់ខ្លួន។

# អំពីអុកស្វាម

អង្គការអុកស្វាម បានធ្វើការគាំទ្រការអភិវឌ្ឍប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ ជាអង្គការដំបូងបង្អស់ ដែលប្រតិបត្តិការក្នុងប្រទេសកម្ពុជាក្រោយការដួល រលំ នៃរបបខ្មែរក្រហម។ អុកស្វាម ធ្វើការយ៉ាងសកម្ម លើកម្មវិធីអភិវឌ្ឍជាច្រើន ក្នុងការលើកកម្ពស់អំណាច សេដ្ឋកិច្ចស្ត្រី ការចិញ្ចឹមជីវិតសម្រាប់ក្រុមងាយរងគ្រោះ កម្មវិធីគ្រប់គ្រងធនធានធម្មជាតិ ការបន្ស៊ាំនឹងការ ប្រែប្រួលអាកាសធាតុ និងថាមពលប្រកបដោយចីរភាព បរិយាប័ន្នហិរញ្ញវត្ថុ កិច្ចគាំពារសង្គម និងការងារ សមរម្យ កសិកម្មបន្ស៊ាំនឹងការប្រែប្រួលអាកាសធាតុ និងប្រកបដោយចីរភាព ការត្រៀមបង្ការគ្រោះមហន្តរាយ និងជំនួយមនុស្សធម៌ ការធ្វើការជាមួយពលរដ្ឋ និង ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ។

បន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហម ក្នុងឆ្នាំ ១៩៧៩ អង្គការអុកស្វាម បានដឹកនាំការគាំទ្រដ៏ពេញទំហឹង ដឹកនាំស្បៀងអាហារ មកជួយប្រជាជន រងគ្រោះនៅប្រទេសកម្ពុជា។



© Jim Howard/Oxf

# សូមអរគុណដៃគូទាំងអស់គ្នា !

អង្គការអុកស្វាម មានសេចក្តីសោមនស្សចំពោះការគាំទ្រ កិច្ចសហការ និងទំនាក់ទំនងយូរអង្វែងជាមួយដៃគូទាំងអស់។ សូមអរគុណ ដែលបានចូលរួមសកម្មភាព ជាមួយអង្គការអុកស្វាម និងបានដើរតួរជាភ្នាក់ងារជម្រុញការផ្លាស់ប្តូរដ៏សំខាន់ ដើម្បីកាត់បន្ថយភាពក្រីក្រ និងពង្រឹងអំណាចសហគមន៍។ យើងបានធ្វើដំណើរជាមួយគ្នា ដើម្បីបង្កើតសន្តិភាព និងធានាយុត្តិធម៌សង្គម។ អុកស្វាម មានមោទនៈភាពជាខ្លាំងសម្រាប់ប្រតិបត្តិការ និងកិច្ចសហការ ជាបន្តបន្ទាប់ជាច្រើនឆ្នាំកន្លងមក ហើយសង្ឃឹមថា យើងនឹងបន្តដំណើររួមគ្នាជាច្រើនឆ្នាំទៅមុខទៀត។

ផ្ទះលេខ ៩៤ ផ្លូវសហព័ន្ធរុស្ស៊ី
សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក
រាជធានីភ្នំពេញ

ទូរស័ព្ទ: (+៨៥៥) ២៣ ៨៨៥ ៤១២
PineehPinooh.Cambodia@oxfam.org

F: OxfaminCambodia
T: OxfamKH
Y: OxfamKH